គ.ជ.ប

# ព្រឹត្តិបត្រ

## គោលនយោបាយរបស់គណបក្សនយោបាយ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ( គ.ជ.ប )

ចេញផ្សាយថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៤ លេខ ១

## ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤

ថ្ងៃបោះឆ្នោត ៖ ថ្ងៃអាទិត្យ ទី២៦ ខែឧសភា ឆ្នាំ២០២៤

អាសយដ្ឋាន : អគារ គ.ជ.ប វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ
ទូរសព្ទ (Tel) : (+855) 23 235 271
អ៊ីម៉ែល (Email) : info@nec.gov.kh
គេហទំព័រ (Website) : www.nec.gov.kh, voterlist.nec.gov.kh
Facebook/YouTube : National Election Committee
Mobile APP : NEC KH, CamNEC News

# មាតិកា

ទំព័រ


• គណបក្ស ឆន្ទៈខ្មែរ ........................................................................................ ១ - ៣

• គណបក្សខ្មែររួបរួមជាតិ ........................................................................................ ៤ - ៦

• គណបក្សហ៊្វុនស៊ិនប៉ិច ........................................................................................ ៧ - ៩

• លិខិតរបស់គណបក្ស កម្លាំងជាតិ ........................................................................... ១០

• គោលការណ៍ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃកម្មវិធីស្មើភាព ............. ១១ - ១២

• គណបក្សប្រជាជនកម្ពុជា ........................................................................................ ១៣ - ១៥

# គណបក្ស ឆន្ទៈខ្មែរ
## KHMER WILL PARTY
សាមគ្គី គង់វង្ស ថ្កើងថ្កាន

លេខ.........✓.........គ.ឆ.ខ.

## គោលនយោបាយគណបក្ស ឆន្ទៈខ្មែរ
## សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤

**គណបក្ស ឆន្ទៈខ្មែរ** នឹង ៖

១-រៀបចំឱ្យមានសន្តិភាពយូរអង្វែង។

២-ប្រកាន់គោលការណ៍អហិង្សា និងសន្តិវិធី ផ្អែកលើមូលដ្ឋានបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ និងឯកភាពជាតិ ដោយឈរលើស្មារតីនៃកិច្ចព្រមព្រៀងសន្តិភាព ទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។

៣-ធានាការអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដូចមានចែងក្នុងធម្មនុញ្ញ ឱ្យបានត្រឹមត្រូវ។

៤-ប្រកាន់យកគោលការណ៍យុត្តិធម៌សង្គម ដោយរដ្ឋត្រូវធានាឱ្យប្រជាពលរដ្ឋ ទទួលបាននូវសិទ្ធិសេរីភាព ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ និងមានឱកាសស្មើគ្នាក្នុងវិស័យនយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច។

៥-ក្នុងអាណត្តិទី៤នេះ **គណបក្ស ឆន្ទៈខ្មែរ** នឹងយកគោលនយោបាយសេដ្ឋកិច្ចជាអាទិភាព។

**<u>ការដោះស្រាយបញ្ហាសេដ្ឋកិច្ច</u>**

គណបក្ស ឆន្ទៈខ្មែរ ប្រកាន់យកគោលការណ៍អភិវឌ្ឍន៍ប្រទេសប្រកបដោយនិរន្តរភាព ដែលជំរុញឱ្យមានការពង្រឹងការផលិតសម្រាប់នាំចេញ ប្រកបដោយភាពរឹងមាំ និងមានការប្រកួតប្រជែង។

**អង្គហេតុ និងបញ្ហាចម្បង**

-កម្ពុជា ជាប្រទេសក្រីក្រក្នុងតំបន់អាស៊ានទន្ទឹមគ្នានឹងភូមា (មីយ៉ាន់ម៉ា)

-ក្នុងរយៈពេល ៣០ឆ្នាំចុងក្រោយនេះ សេដ្ឋកិច្ចកម្ពុជាមានកំណើនទាប បើប្រៀបធៀបនឹងប្រទេសជិតខាងក្នុងតំបន់។

- ជាការពិត កម្ពុជាសព្វថ្ងៃ កំពុងជួបវិបត្តិសេដ្ឋកិច្ច ដូចជា៖
  - -បញ្ហាបំណុល
  - -បញ្ហាទីផ្សារការងារ
  - -បញ្ហាចំណូលប្រជាពលរដ្ឋទាប...។ល។

ទីស្នាក់ការកណ្តាល៖ បុរីប៉េងហួត បឹងស្នោរ ផ្ទះលេខ 06 ផ្លូវ R05 សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ
Address: Borey Peng Huoth Boeung Snor Home 06 Street R05 Sangkat Veal Sbov Khan Chbar Ampov, Phnom Penh, Cambodia

**-វិស័យកសិកម្ម**

- ប្រព័ន្ធធារាសាស្ត្រ ទន់ខ្សោយ (មានប្រឡាយ តែអត់ទឹក នៅរដូវប្រាំង)
- ទីផ្សារកសិផលមានទំហំតូចណាស់ ភាគច្រើនពឹងផ្អែកលើប្រទេសជិតខាង ដែលនាំឱ្យកសិផល ដែលលក់បានមានតម្លៃទាប និងគ្មានភាពនឹងនរ ដូចជាតម្លៃស្រូវ តម្លៃសាច់ជ្រូកជាដើម។

**- ផលិតកម្មឧស្សាហកម្ម**

**យើងស្ទើរតែគ្មានឧស្សាហកម្មកែច្នៃវត្ថុធាតុដើមកសិកម្ម** ហើយវិស័យនេះហើយដែលជាមូលដ្ឋានចម្បង សម្រាប់ផ្គត់ផ្គង់ការងារដល់ប្រជាពលរដ្ឋនៅតាមជនបទ និងជួយឱ្យរក្សាបាននូវស្ថិរភាពតម្លៃកសិផល។

**វិស័យវាយនភ័ណ្ឌ**ធ្លាក់ចុះ ហើយ**ដើម្បីឲ្យវិស័យនេះដំណើរការល្អឡើងវិញ** ទាល់តែកម្ពុជាទទួលបានមកវិញនូវប្រព័ន្ធអនុគ្រោះពន្ធអឺរ៉ុប(EBA) និងប្រព័ន្ធអនុគ្រោះពន្ធអាមេរិក(GSP)។ ដើម្បីទទួលបានប្រព័ន្ធអនុគ្រោះពន្ធនេះ ទាល់តែមានការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស។

**-វិស័យសំណង់ និងអចលនទ្រព្យ** ក៏មានការរាំងស្ទះដែរ ដោយសារចំណូលប្រជាជន មានការធ្លាក់ចុះហើយលំហូរសាច់ប្រាក់នៅតាមធនាគារ ក៏មានកម្រិតតិចតួច។

សរុបមក **គ្រឹះសេដ្ឋកិច្ច**កម្ពុជា មានភាពទន់ខ្សោយ មិនអាចប្រកួតប្រជែងជាមួយប្រទេសនានា និងមិនអាចប្រឈមនឹងវិបត្តិសេដ្ឋកិច្ចសកល បានឡើយ។ ដូច្នេះហើយ បានជា**ប្រាក់ចំណូលរបស់ពលរដ្ឋកម្ពុជា** យើងនៅមានកំរិតទាប ហើយ**ទីផ្សារការងារកម្ពុជាយើង**តូចចង្អៀត មិនអាចផ្តល់ការងារគ្រប់គ្រាន់ដល់ពលរដ្ឋបានទេ ជាពិសេសយុវជន ដែលចូលមកក្នុងទីផ្សារការងារប្រមាណ ៣ សែននាក់បន្ថែមទៀត ជារៀងរាល់ឆ្នាំ។ ជាលទ្ធផលពួកគេបង្ខំចិត្តធ្វើចំណាកស្រុកទៅប្រទេសថៃ ដើម្បីស្វែងរកការងារធ្វើ។

**ដូច្នេះតើ គណបក្ស ឆន្ទៈខ្មែរ ដែលបានទទួលបេសកកម្មពី គណបក្ស ភ្លើងទៀន ត្រូវដោះស្រាយបញ្ហាសេដ្ឋកិច្ចយ៉ាងដូចម្តេច?**

**១-កាត់បន្ថយថ្លៃដើមផលិតកម្មតាមរយៈ ៖**

- **បញ្ចុះតម្លៃអគ្គិសនី**ដល់កំរិតប្រហាក់ប្រហែលប្រទេសជិតខាង; ពោលគឺ ៤០០ រៀល/គីឡូវ៉ាត់ សម្រាប់ប្រជាជនទូទៅ និង ១០០ រៀល/គីឡូវ៉ាត់ សម្រាប់អ្នកប្រើប្រាស់តិច។
- កាត់បន្ថយថ្លៃដឹកជញ្ជូន តាមរយៈ ៖
  - ការកែលម្អស្ថានភាពផ្លូវ និងស្ពាន
  - ការវិនិយោគលើប្រព័ន្ធផ្លូវដែក
  - ស្តារឡើងវិញនូវផ្លូវទឹក សម្រាប់ការដឹកជញ្ជូនដែលមានតម្លៃទាប។

**២-កម្ពុជាត្រូវពង្រីកលំហសេរីភាពនយោបាយ និងពង្រឹងលទ្ធិប្រជាធិបតេយ្យ** ឱ្យបានល្អឡើងវិញ ដើម្បីទទួលបានប្រព័ន្ធអនុគ្រោះពន្ធអឺរ៉ុប (EBA) និងប្រព័ន្ធអនុគ្រោះពន្ធអាមេរិក (GSP)

**៣-ពង្រីក និងពង្រឹងនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ** ដើម្បីឱ្យមានការចូលរួមដឹកនាំសកម្មពីសំណាក់ប្រជាជនមូលដ្ឋាន។

៤-អន្តរាគមន៍សេដ្ឋកិច្ចដោយផ្ទាល់ក្នុងវិស័យកសិកម្ម ៖

- មិនយកពន្ធ លើវិស័យកសិកម្ម និងឧស្សាហកម្មកែច្នៃ កសិកម្ម និងម្ហូបអាហារ
- វិនិយោគដោយមូលនិធិសាធារណៈ និងឧបត្ថម្ភធនធានមួយចំនួន សម្រាប់ឧស្សាហកម្ម ចំណីអាហារ និងកសិកម្មកែច្នៃ។

**គោលនយោបាយកិច្ចការបរទេស ៖**

ដើម្បីឱ្យការអនុវត្តនូវគោលនយោបាយក្នុងស្រុកខាងលើ ជាពិសេសគោលនយោបាយទាក់ទង ទៅនឹងបញ្ហាសេដ្ឋកិច្ចនេះទទួលបានជោគជ័យ

- នយោបាយការបរទេសរបស់កម្ពុជា ត្រូវតែប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវ អព្យាក្រឹតភាព និង តុល្យភាពរវាងលោកខាងកើត និងលោកខាងលិច។
- សំខាន់បំផុត កម្ពុជាត្រូវមាន ការបង្រួបបង្រួមជាតិ ការផ្សះផ្សាជាតិ និងឯកភាពជាតិ ស្របតាមស្មារតី នៃកិច្ចព្រមព្រៀងសន្តិភាព ទីក្រុងប៉ារីស ឆ្នាំ១៩៩១។

# គណបក្សខ្មែររួបរួមជាតិ

ឯករាជ្យ សន្តិភាព យុត្តិធម៌

**ព្រឹត្តិបត្រ** *លេខ ០០១*

## គោលនយោបាយ
## គណបក្សខ្មែររួបរួមជាតិ

**គណបក្សខ្មែររួបរួមជាតិ** បង្កើតឡើងក្នុងគោលបំណងបង្រួបបង្រួមជាតិខ្មែរពីគ្រប់និន្នាការនយោបាយ គ្រប់មជ្ឈដ្ឋាន គ្រប់ស្រទាប់វណ្ណៈ ដោយមិនរើសអើងភេទ ពណ៌សម្បុរ ពូជសាសន៍ និងធ្វើឱ្យមានការសាមគ្គីឯកភាពជាតិតែមួយ ដើម្បីរួមគ្នាដោះស្រាយបញ្ហានានាដែលប្រទេសជាតិ និងប្រជាពលរដ្ឋកំពុងជួបការប្រឈម ព្រមទាំងរួមគ្នាកសាងសង្គមមួយស្អាតស្អំ យុត្តិធម៌ រីកចម្រើនរុងរឿង ដូចនេះគណបក្សខ្មែររួបរួមជាតិបានកំណត់យ៉ាងច្បាស់លាស់អំពីគោលនយោបាយអាទិភាពរបស់ខ្លួន ក្នុងការអនុវត្តការងារឱ្យទទួលបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់ ក្នុងការឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋ និងការបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋ តាមគោលនយោបាយដូចខាងក្រោមៈ

**១-បង្រួបបង្រួមជាតិៈ** គណបក្សខ្មែររួបរួមជាតិមានគោលនយោបាយបង្រួបបង្រួមជាតិខ្មែរ រវាងជនរួមជាតិខ្មែរ និងជនជាតិខ្មែរ ឱ្យមានសាមគ្គីភាពជាធ្លុងមួយ មានការផ្សះផ្សាជាតិ និងមានឯកភាពជាតិ ឆ្ពោះទៅរកយុត្តិធម៌សង្គម រក្សាការពារមាតុភូមិកម្ពុជា ធានានូវប្រជាធិបតេយ្យគោរពសិទ្ធិមនុស្ស ក្នុងនាមកូនខ្មែរជាម្ចាស់នៃប្រទេសជាតិទាំងមូល។

**២-ការគ្រប់គ្រងរដ្ឋៈ** ជំរុញឱ្យមានការបែងចែកអំណាច ទាំងបីឱ្យដាច់ចេញពីគ្នា និងស្នើឱ្យមានអំណាចបន្ថែម១ទៀត គឺ អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ អំណាចតុលាការ និងអំណាចសារព័ត៌មាន។

**៣-កំណែទម្រង់ៈ** ការធ្វើកំណែទម្រង់លើគ្រប់វិស័យដែលមានភាពអសកម្ម ឬភាពខ្វះខាត ដូចជា វិស័យនៃប្រព័ន្ធយុត្តិធម៌ (តុលាការស្អាតស្អំ) ប្រព័ន្ធសុខាភិបាល (មន្ទីរពេទ្យមានសេវាកម្មល្អគ្រូពេទ្យមានជំនាញច្បាស់លាស់ និងមានក្រមសីលធម៌) ពង្រឹងលើវិស័យ អប់រំឱ្យក្លាយទៅជាស្តង់ដារ និងមានគុណភាពអប់រំ។

**៤-ពង្រីកសេដ្ឋកិច្ចៈ** ក្នុងគោលបំណងដោយកាត់បន្ថយភាពក្រីក្រតាមរយៈនៃការបង្កើនសេដ្ឋកិច្ចជាតិ ដោយផ្តោតលើវិស័យ កសិកម្ម មានអង្ករ ពោត សណ្តែក ដំឡូង ជាពិសេសបន្លែ ផ្លែឈើ និងការចិញ្ចឹមសត្វផងដែរ បង្កើនកសិផលក្នុងស្រុក កាត់បន្ថយការនាំចូល កសិកម្មពីបរទេស។ ការកៀរគរ អ្នកវិនិយោគិនពីក្រៅ

ប្រទេសមកវិនិយោគក្នុងប្រទេស និងការលើកទឹកចិត្ត ការគាំពារដល់ សហគ្រិនក្នុងស្រុកឱ្យមានភាពរស់រវើក និងមានលទ្ធភាពនាំចេញទៅក្រៅប្រទេសបានកាន់តែច្រើន។

**៥-គោរពសិទ្ធិមនុស្ស៖** គណបក្សខ្មែររួបរួមជាតិលើកទឹកចិត្តដល់ ប្រជាពលរដ្ឋឱ្យទទួលបាននូវសិទ្ធិសេរីភាពពេញលេញ គ្មានការគាបសង្កត់ គ្មានការគំរាមកំហែង ទទួលបានសេរីភាពក្នុងការបញ្ចេញមតិ ទទួលបាននូវសិទ្ធិទទួលព័ត៌មាន និងជាពិសេសជំរុញឱ្យយុវជន ស្ត្រីចូលរួមក្នុងកិច្ចការសង្គមជាតិ ដូចជាការងារនយោបាយដោយធានាសុវត្ថិភាពដល់អ្នកនយោបាយជាដើម។

**៦-ប្រព័ន្ធអប់រំស្តង់ដារ៖** បង្កើតឱ្យមានកម្មវិធីអប់រំគំរូ ជំរុញឱ្យសិស្សរៀនទាបបំផុតបញ្ចប់មធ្យមសិក្សាទុតិយភូមិ ជំរុញឱ្យក្រសួងមានកម្ចីសម្រាប់និស្សិតដែលមានបំណងបន្តការសិក្សាទៅឧត្តមសិក្សានិងធានាឱ្យមានការងារសម្រាប់និស្សិត ដើម្បីឱ្យមានលទ្ធភាពបង់សងថ្លៃសិក្សាក្រោយពេលបញ្ចប់ការសិក្សា និងមានការងារធ្វើ។

**៧-សង្គមកិច្ច៖** គណបក្សខ្មែររួបរួមជាតិ បង្កើតមណ្ឌលសម្រាប់ចាស់ជរា បង្កើតមូលនិធិ និងមជ្ឈមណ្ឌលគាំពារ សម្រាប់ជនក្រីក្រ ជនពិការភាព កុមារកំព្រា កម្មករ កម្មការនី ព្រះសង្ឃ សម្រាកព្យាបាលនៅមន្ទីរពេទ្យរដ្ឋដោយឥតគិតថ្លៃ។

**៨-ប្រឆាំងអំពើពុករលួយ៖** គណបក្សខ្មែររួបរួមជាតិប្រឆាំងដាច់ខាតចំពោះជនប្រព្រឹត្តអំពើពុករលួយ ការកាប់បំផ្លាញធនធានធម្មជាតិ ការប្រើប្រាស់ និងជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស គ្មានក្មេងទំនើង គ្មានការប្រើអំពើហិង្សាក្នុងគ្រួសារជាដើម ។

**៩-ពង្រឹងកិច្ចសហប្រតិបត្តិការ៖** គណបក្សខ្មែររួបរួមជាតិ នឹងពិនិត្យសើរើអំពីច្បាប់ និងរឹតបន្តឹងច្បាប់អន្តោប្រវេសន៍ លើជនអន្តោប្រវេសន៍ខុសច្បាប់ដែលចូលមករស់នៅ និងបន្តមករស់នៅក្នុងប្រទេសកម្ពុជា។

## អំពីមាគ៌ា

## " ប្រជាធិបតេយ្យសេរីបែបរួបរួមជាតិ "

**គណបក្សខ្មែររួបរួមជាតិ៖** ដោយមើលឃើញអំពីភាពមិនចុះសម្រុងគ្នាក្នុងនាមអ្នកនយោបាយខ្មែរពីសម័យកាលមួយទៅសម័យកាលមួយ រហូតមកដល់បច្ចុប្បន្ននេះ ការវាយប្រហារតាមរយៈវោហាសាស្ត្រ ការជេរប្រមាថ លាបពណ៌ មួលបង្កាច់ ញុះញង់គ្នាទៅវិញទៅមកដោយឥតស្រាកស្រាន្ត ធ្វើឱ្យគ្មានអ្វីចំណេញដល់សង្គមជាតិ និងប្រជាពលរដ្ឋ ផ្ទុយទៅវិញមានតែបង្កការលំបាកទៅដល់ប្រជាពលរដ្ឋស្លូតត្រង់ទៅវិញ ហើយថែមទាំងបង្កើតឱ្យមានអំពើពុករលួយ អំពើអយុត្តិធម៌សង្គម និងការបាត់បង់កិត្តិយសប្រទេសក្នុងឆាកអន្តរជាតិជាដើម ទាំងអស់នេះគឺមកពីការខ្វះភាពសាមគ្គីជាតិ និងការគិតផលប្រយោជន៍ជាតិជាធំ ដោយមើលឃើញបញ្ហាជាច្រើនបែបនេះ ទើបជំរុញឱ្យថ្នាក់ដឹកនាំនៃ **គណបក្សខ្មែររួបរួមជាតិ** បានជួបពិភាក្សារកដំណោះស្រាយរួមមួយ ដើម្បីឱ្យយើងដែលជាជនជាតិខ្មែររស់នៅក្នុងទឹកដីកំណើតរបស់ខ្លួន អាចរស់នៅ

បានល្អប្រសើរ ការនិយាយប្រកបដោយ សីលធម៌ គុណធម៌សង្គម ជាពិសេស ការសាមគ្គីជាតិ ការផ្សះផ្សាជាតិ ឯកភាពជាតិ និងការបង្រួបបង្រួមជាតិ ពិតប្រាកដមួយដែលអាចឱ្យអ្នកនយោបាយខ្មែរ សាងផលប្រយោជន៍ដល់ប្រទេសជាតិ និងប្រជាពលជាតិខ្មែរ ជាអនេក។

## ការជជែកពិភាក្សា បង្កើតមាគ៌ានយោបាយ



ទន្ទឹមនឹងនេះ ការជជែកពិភាក្សាថ្នាក់ដឹកនាំ **គណបក្សខ្មែររួបរួមជាតិ** ក្រោមការចូលរួមពីប្រធានគណបក្ស ឯកឧត្តម **ញឹក ប៊ុនឆៃ** ក៏សម្រេចបង្កើតមាគ៌ានយោបាយថ្មីមួយ នៅថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០២៤ កន្លងទៅនេះ បានសម្រេចយកមាគ៌ានយោបាយ " **ប្រជាធិបតេយ្យសេរីបង្រួបបង្រួមជាតិ** " សម្រាប់គណបក្សរបស់ខ្លួន ដើម្បីឆ្លុះបញ្ចាំងអំពីបរិបទនៃបរិយាកាសនយោបាយកម្ពុជាសព្វថ្ងៃ ដូច្នេះ ដើម្បីឱ្យយល់កាន់តែច្បាស់ពីអត្ថន័យនៃ មាគ៌ានយោបាយខាងលើ សូមឈ្វេងយល់នូវពាក្យមួយចំនួនខាងក្រោម ៖

- **ប្រជាធិបតេយ្យសេរី៖** គឺការគោរពនូវសិទ្ធិមនុស្ស ប្រជាពលរដ្ឋជាធំ ប្រជាពលរដ្ឋជាអ្នកមានអំណាច ហើយមានសិទ្ធិសេរីក្នុងការបញ្ចេញមតិរិះគន់ ប្រជាពលរដ្ឋជាអធិបតី និងជាម្ចាស់។
- **បង្រួបបង្រួម៖** ធ្វើឱ្យរួមមូលគ្នាវិញ រួបរួម សាមគ្គី ។
- **ជាតិ៖** គឺសំដៅដល់ជាតិនៃកម្ពុជា ឬជាតិខ្មែរ។

សរុបសេចក្តី " **ប្រជាធិបតេយ្យសេរីបង្រួបបង្រួមជាតិ** " គឺការប្រមូលផ្តុំ អ្នកស្នេហាជាតិ អ្នកស្រឡាញ់ជាតិខ្មែរ ឱ្យរួបរួមគ្នា សាមគ្គីគ្នា និងឯកភាពគ្នា ដឹកដៃគ្នាឆ្ពោះទៅអភិវឌ្ឍសង្គមជាតិ និងស្វែងរកផលប្រយោជន៍ជូនប្រជាពលរដ្ឋកម្ពុជា ឱ្យកាន់តែប្រសើរឡើង។

# ព្រះសារលិខិត

## ព្រះអង្គម្ចាស់ នរោត្តម ចក្រាវុធ ប្រធានគណបក្ស ហ៊្វុនស៊ិនប៉ិច
## ក្នុងឱកាសបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សា អាណត្តិទី៤ ឆ្នាំ២០២៤

ខ្ញុំព្រះករុណា **នរោត្តម ចក្រាវុធ ប្រធានគណបក្សហ៊្វុនស៊ិនប៉ិច**

- សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ
- សូមជម្រាបសួរ បងប្អូនជនរួមជាតិជាទីគោរពស្នេហាដ៏ខ្ពង់ខ្ពស់
- សូមជម្រាបសួរ សហជីវិន សហជីវិនី នៃគណបក្សហ៊្វុនស៊ិនប៉ិច ជាទីមេត្រី!



នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៤ ខាងមុខនេះ គឺជាការបោះឆ្នោតដើម្បីជ្រើសរើសក្រុមប្រឹក្សា ជាតំណាងដល់បងប្អូនជនរួមជាតិនៅមូលដ្ឋាន ដើម្បីគ្រប់គ្រង ដឹកនាំរដ្ឋបាលតាមបែបផែនវិមជ្ឈការ និង វិសហមជ្ឈការ ឱ្យមានលក្ខណៈប្រសើរឡើង។ ថ្វីត្បិតតែការជ្រើសរើសក្រុមប្រឹក្សាប្រព្រឹត្តទៅរៀងរាល់៥ឆ្នាំម្តង តែផលប៉ះពាល់នៃសេចក្តីសម្រេចចិត្តនេះ នឹងមានឥទ្ធិពលយ៉ាងខ្លាំង និង យូរអង្វែងទៅលើជីវភាព និង សុខសុវត្ថិភាពផ្ទាល់របស់បងប្អូនជនរួមជាតិ។

ក្នុងគោលបំណងលើកកម្ពស់ និង ថែរក្សាកេរ្តិ៍រតកដ៏ថ្លៃថ្លារបស់ ព្រះបិតាស្ថាបនិកគណបក្សហ៊្វុនស៊ិនប៉ិច និងស្នាព្រះហស្តដឹកនាំកសាងជាតិរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ**

និង ដើម្បីបម្រើ ការពារ អភិវឌ្ឍន៍តាមមូលដ្ឋាន ខ្ញុំ **នរោត្តម ចក្រាវុធ ប្រធានគណបក្សហ្វ៊ុនស៊ិនប៉ិច** សូមបញ្ជាក់ជូនជាថ្មីថា គណបក្សហ្វ៊ុនស៊ិនប៉ិច បានដាក់ចេញគោលនយោបាយអាទិភាពរួចជាស្រេច សម្រាប់ក្រុមប្រឹក្សា របស់គណបក្ស ហ្វ៊ុនស៊ិនប៉ិច យកទៅអនុវត្ត ក្រោយពេលទទួលបានការគាំទ្រពីអ្នកបោះឆ្នោត។ ការបម្រើសេវាសាធារណៈ ការលើកកម្ពស់ជីវភាព ការថែរក្សាសុខុមាលភាព ការអភិវឌ្ឍន៍នៅមូលដ្ឋាន ការបំបាត់អំពើអបាយមុខ អំពើអយុត្តិធម៌ ទាំងនេះសុទ្ធតែជាបញ្ហាដែលកំពុងប្រឈម និង ពុំទាន់បានឆ្លើយតបឱ្យអស់ពីសមត្ថភាព និង ទៅតាមតម្រូវការរបស់ប្រជារាស្ត្រនៅឡើយ។

ដើម្បីដោះស្រាយបញ្ហាទាំងឡាយនេះ ខ្ញុំព្រះករុណាខ្ញុំ **នរោត្តម ចក្រាវុធ** សូមអំពាវនាវដល់អ្នកបោះឆ្នោតទាំងអស់ សូមមេត្តាអញ្ជើញទៅបោះឆ្នោតឱ្យបានគ្រប់ៗគ្នា ហើយបោះឆ្នោតជូនគណបក្សហ្វ៊ុនស៊ិនប៉ិច ដើម្បីបម្រើការពារផលប្រយោជន៍ប្រជារាស្ត្រ ដោយភាពស្មោះត្រង់ និង គ្មានការរើសអើង។

*សូមអរព្រះគុណនិងអរគុណ*

ថ្ងៃសុក្រ ១០កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៤

**ប្រធានគណបក្សហ្វ៊ុនស៊ិនប៉ិច**

**ព្រះអង្គម្ចាស់ នរោត្តម ចក្រាវុធ**

# គណបក្ស ហ្វ៊ុនស៊ិនប៉ិច



ព្រះអង្គម្ចាស់ **នរោត្តម ចក្រាវុធ** អំពាវនាវ ដល់អ្នកបោះឆ្នោត មេត្តាបោះឆ្នោតជូន គណបក្ស ហ្វ៊ុនស៊ិនប៉ិច ដើម្បីបម្រើការពារផលប្រយោជន៍ប្រជារាស្ត្រ ដោយភាពស្មោះត្រង់ និងគ្មានការរើសអើង។

✓ **បោះឆ្នោតជូន គណបក្ស ហ្វ៊ុនស៊ិនប៉ិច**

# គណបក្ស កម្លាំងជាតិ

**NATION POWER PARTY**

**សិទ្ធិមនុស្ស យុត្តិធម៌ ឯកភាពជាតិ**

គណបក្ស កម្លាំងជាតិ

លេខ:.០៧៨/.... គ.ក.ជ
/២៤

**សូមគោរពជូន**

**ឯកឧត្តមប្រធាន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**<u>កម្មវត្ថុ</u>÷** ស្ដីពីការបោះបង់ការចូលរួមក្នុង កម្មវិធីតុមូល កម្មវិធីចាក់ផ្សាយសប្បុតគោលនយោបាយ និងកម្មវិធីចុះផ្សាយ ព្រឹត្តិបត្រគោលនយោបាយ របស់គណបក្ស កម្លាំងជាតិ ។

តបតាមកម្មវត្ថុ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា **គណបក្ស កម្លាំងជាតិ** បានសំរេចបោះបង់ការចូលរួមក្នុង កម្មវិធីតុមូល កម្មវិធីចាក់ផ្សាយសប្បុតគោលនយោបាយ និងកម្មវិធីចុះផ្សាយព្រឹត្តិបត្រគោលនយោបាយរបស់គណបក្ស កម្លាំងជាតិ ដែលរៀបចំដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ នីតិកាលទី៤ ឆ្នាំ២០២៤ ។

សេចក្ដីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាជ្រាបជាព័ត៌មាន ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពស់ខ្ពង់ អំពីខ្ញុំ។

ថ្ងៃសុក្រ ១១កើត ខែចេត្រ ឆ្នាំរោង បញ្ចស័ក ព.ស ២៥៦៧
ស្នាក់ការកណ្ដាលគណបក្ស ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៤

**ប្រធានគណៈកម្មាធិការប្រតិបត្តិគណបក្ស**

គណបក្ស កម្លាំងជាតិ NATION POWER PARTY

**សុខ គឹមសេង**

ទីស្នាក់ការកណ្ដាល ៖ ក្រុមទី១៣ ភូមិក្រចាប់ សង្កាត់អាចារ្យលាក់ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
Tel: 012 6 777 62 / Telegram : 070 70 70 18

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**លេខៈ** ៣៤៧ **គ.ជ.ប**

**គោលការណ៍**
**ស្តីពី**
**ការរៀបចំ និងការប្រព្រឹត្តទៅនៃកម្មវិធីស្មើភាព**
**សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង**
**ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤**

- យោងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- យោងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

## ១. គោលបំណង

កម្មវិធីស្មើភាព ត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដើម្បីឱ្យគណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ នៅតាមមណ្ឌលបោះឆ្នោតនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ហើយដែលបានទទួលស្គាល់ជាផ្លូវការដោយ គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) មានឱកាសផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនជូនដល់អ្នកបោះឆ្នោត ដែលកម្មវិធីនេះត្រូវចាក់ផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ (វិទ្យុជាតិកម្ពុជា និងទូរទស្សន៍ជាតិកម្ពុជា)។

## ២. ការផ្សព្វផ្សាយកម្មវិធីស្មើភាព

កម្មវិធីស្មើភាព ដែលត្រូវចាក់ផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ មានដូចខាងក្រោមៈ

២.១ កម្មវិធីតុមូល ដែលតម្រូវឱ្យគណបក្សនយោបាយឆ្លើយសំណួរទៅតាមប្រធានបទដែលកំណត់ដោយ គ.ជ.ប។

១

២.២ កម្មវិធីស្ប៉តគោលនយោបាយ ដែលផលិតដោយសាមីគណបក្សនយោបាយ។

២.៣ ការបោះពុម្ពផ្សាយអត្ថបទឃោសនា អំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយលើព្រឹត្តិបត្រគោលនយោបាយគណបក្ស ដែលបោះពុម្ពផ្សាយដោយ គ.ជ.ប។

ការរៀបចំកម្មវិធីទាំង ៣ (បី) ខាងលើនេះ ត្រូវស្ថិតក្រោមការរៀបចំ ចាត់ចែង និងពិនិត្យដោយគណៈកម្មការសម្របសម្រួល។

## ៣. ការអនុវត្តគោលការណ៍

ការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤ ត្រូវអនុវត្តតាមគោលការណ៍ស្មើភាព ដោយគណបក្សនយោបាយនីមួយៗទទួលបានម៉ោងផ្សាយតាមវិទ្យុជាតិកម្ពុជា និងទូរទស្សន៍ជាតិកម្ពុជាស្មើៗគ្នា ហើយរយៈពេលនេះនឹងត្រូវចាក់ផ្សាយឡើងវិញក្នុងថ្ងៃដដែល។

## ៤. ការទទួលខុសត្រូវរបស់គណបក្សនយោបាយ

គណបក្សនយោបាយ ត្រូវគោរពតាមការរៀបចំ និងចាត់ចែងដោយគណៈកម្មការសម្របសម្រួល ដែលរៀបចំការចាប់ឆ្នោតយកលំដាប់លេខរៀងមុនក្រោយសម្រាប់ការថត ទីកន្លែងអង្គុយ ម៉ោងផ្សាយ លេខរៀងផ្សាយ និងគោរពតាមបទបញ្ជាគុម្ពល សម្រាប់ការថតកម្មវិធី។

គណបក្សនយោបាយដែលចូលរួមក្នុងកម្មវិធីស្មើភាព ត្រូវតែគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត និងគោរពតាមគោលការណ៍នេះ។

## ៥. ការទទួលខុសត្រូវខ្លឹមសារផ្សព្វផ្សាយ

គ.ជ.ប ជាអ្នកទទួលខុសត្រូវលើខ្លឹមសារផ្សព្វផ្សាយកម្មវិធីស្មើភាព ដែលរៀបចំឡើងដោយ គ.ជ.ប។

ថ្ងៃព្រហស្បតិ៍ ៤ រោច ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ មិនា ឆ្នាំ២០២៤

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**

២



# គោលការណ៍សំខាន់ៗ
# នៃកម្មវិធីនយោបាយរបស់គណបក្សប្រជាជនកម្ពុជា
# សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ អាណត្តិទី៤

**គណបក្សប្រជាជនកម្ពុជា** ត្រូវបានបង្កើតឡើងនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ១៩៥១ ដោយមានប្រភពពីចលនាតស៊ូរបស់ប្រជាជនកម្ពុជាប្រឆាំងអាណានិគមនិយមបារាំងដើម្បីឯករាជ្យជាតិ។ ចាប់ពីថ្ងៃបដិសន្ធិមក គណបក្សប្រជាជនកម្ពុជា បានប្រកាន់ខ្ជាប់នូវគោលបំណង និងឧត្តមគតិរបស់ខ្លួន គឺផ្សារភ្ជាប់ រួមសុខ រួមទុក្ខ ជាមួយប្រជាជនពុះពារ ជម្នះរាល់ឧបសគ្គ ធ្វើពលិកម្មឥតរួញរា ដើម្បីកសាងប្រទេសកម្ពុជាមួយ**ឯករាជ្យ សន្តិភាព សេរីភាព អព្យាក្រឹត ប្រជាធិបតេយ្យ និងវឌ្ឍនភាពសង្គម។**

ក្នុងកាលៈទេសៈដែលប្រទេសជាតិត្រូវធ្លាក់ក្នុងគ្រោះមហន្តរាយប្រល័យពូជសាសន៍ ដែលបង្កឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យរបស់ពួកប៉ុល ពត គណបក្សប្រជាជនកម្ពុជា គឺជាកម្លាំងនយោបាយតែមួយគត់ដែលបានក្រោកឈរ តស៊ូដឹកនាំប្រជាជនប្រយុទ្ធផ្តួលរំលំរបបដ៏យង់ឃ្នងនេះរហូតទទួលបានជ័យជម្នះជាប្រវត្តិសាស្ត្រនាថ្ងៃទី៧ ខែមករា ឆ្នាំ ១៩៧៩ ធ្វើឱ្យប្រជាជាតិខ្មែរបានរស់ឡើងវិញ ទទួលបានសិទ្ធិសេរីភាពពេញលេញ ស្ថិតស្ថេរគង់វង្ស និងមានការអភិវឌ្ឍរីកចម្រើនមកដល់បច្ចុប្បន្ន។

ការពិតជាក់ស្តែងបានបង្ហាញថា រយៈពេល ៤៥ឆ្នាំ កន្លងទៅនេះ បន្ទាប់ពីជ័យជម្នះលើរបបប្រល័យពូជសាសន៍ **គណបក្សប្រជាជនកម្ពុជា** ដែលមាន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាអគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើម បានដឹកនាំប្រទេសជាតិឆ្លងកាត់ឧបសគ្គ និងការលំបាករាប់មុឺនជំពូកប្រកបដោយជោគជ័យ ធ្វើឱ្យសង្គមជាតិទាំងមូលមានការផ្លាស់ប្តូរយ៉ាងជ្រាលជ្រៅដែលពុំនឹកស្មានដល់ ជាពិសេសក្នុងរយៈពេល២៥ឆ្នាំចុងក្រោយនេះ បន្ទាប់ពីកម្ពុជាមានសន្តិភាពពេញលេញ។ កម្ពុជាដែលពីមុនកើតមានសង្គ្រាមមិនចេះចប់ និងជាទឹកដីនៃវាលពិឃាដដ៏យង់ឃ្នងបំផុត បានប្រែក្លាយទៅជាទឹកដីដ៏ស្រស់បំព្រងប្រកបដោយសន្តិភាព សេរីភាព ប្រជាធិបតេយ្យ និងនីតិរដ្ឋ ប្រជាជនបានធ្វើជាម្ចាស់លើជោគវាសនារបស់ខ្លួន ហើយកំពុងរស់នៅយ៉ាងសុខសាន្ត សុខដុមរមនាទាំងក្នុងគ្រួសារ ក្នុងសហគមន៍ និងសង្គមជាតិទាំងមូល។ កម្ពុជាដែលខ្ទេចខ្ទីសេដ្ឋកិច្ច សង្គម ត្រូវបំផ្លាញខ្ទេចខ្ទីដល់ឬសគល់ បានក្លាយជាទឹកដីដែលមានការអភិវឌ្ឍលើគ្រប់វិស័យប្រកបដោយចីរភាព និងសមធម៌ ហើយបានចេញផុតពីប្រទេសមានចំណូលទាប ក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាប ធ្វើឱ្យប្រជាជនមានជីវភាពកាន់តែប្រសើរឡើង និងមានក្តីសង្ឃឹមចំពោះអនាគត។ កម្ពុជាដែលធ្លាប់តែត្រូវគេឈ្លានពាន ប្រមាថ ត្រូវគេហ៊ុមព័ទ្ធ និងឯកោ ឥឡូវនេះ គឺជារដ្ឋមួយដែលមានឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដីពេញលេញ បានធ្វើសមាហរណកម្ម

ខ្លួនទៅក្នុងតំបន់ និងពិភពលោក ហើយបាននិងកំពុងចូលរួមយ៉ាងសកម្មក្នុងរាល់កិច្ចការអន្តរជាតិ ដោយស្មើភាព និងស្មើសិទ្ធិ ធ្វើឱ្យកិត្យានុភាពជាតិបានលេចត្រដែតលើឆាកអន្តរជាតិ។ ព្រមជាមួយនោះ ក្នុងពេលត្រូវប្រឈមនឹងការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ កម្ពុជាបានខិតខំពង្រឹងខឿនការពារសុខភាពរបស់ប្រជាជន ហើយបានក្លាយជាប្រទេសឈានមុខមួយនៅលើពិភពលោកក្នុងការប្រយុទ្ធទប់ស្កាត់ជំងឺដ៏កាចសាហាវនេះ ការពារបាននូវអាយុជីវិតរបស់ប្រជាជន រក្សាបានស្ថិរភាពជីវភាព ស្ថិរភាពសេដ្ឋកិច្ច និងធ្វើឱ្យសេដ្ឋកិច្ចជាតិអាចងើបឡើងវិញយ៉ាងឆាប់រហ័ស។

លើមូលដ្ឋានសមិទ្ធផលជាប្រវត្តិសាស្ត្រដ៏ថ្លៃថ្លាទាំងអស់នេះ បានធ្វើឱ្យប្រជាជននៅទូទាំងប្រទេសមានជំនឿយ៉ាងមុតមាំចំពោះការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ហើយបានបោះឆ្នោតគាំទ្រគណបក្សប្រជាជនកម្ពុជាឱ្យទទួលបានជ័យជម្នះយ៉ាងត្រចះត្រចង់បំផុតក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧។

មកដល់ពេលនេះ ជាមួយនឹងការអបអរសាទរ និងគាំទ្រយ៉ាងកក់ក្ដៅពីប្រជាជននៅទូទាំងប្រទេស រាជរដ្ឋាភិបាល នីតិកាលទី៧ ដឹកនាំដោយ សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** កំពុងបំពេញការងាររបស់ខ្លួនយ៉ាងសកម្មប្រកបដោយប្រសិទ្ធភាព សម្រេចបានសមិទ្ធផលធំៗថ្មីៗទៀតជូនជាតិ និងប្រជាជន ក្នុងការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដើម្បី កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព។ ផ្អែកលើតថភាពជាប្រវត្តិសាស្ត្រទាំងនេះ បានឆ្លុះបញ្ចាំងឱ្យឃើញច្បាស់ថា ព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងធ្វើដំណើរទៅមុខយ៉ាងលឿនលើមាគ៌ាដ៏ត្រឹមត្រូវឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង។

ដើម្បីបន្តបុព្វហេតុកសាង និងការពារមាតុភូមិកម្ពុជាឱ្យសម្រេចបានសមិទ្ធផលធំៗថ្មីៗទៀត ជាពិសេសការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សម្រាប់អាណត្តិទី៤នៃក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ **គណបក្សប្រជាជនកម្ពុជា** មានគោលការណ៍ដូចតទៅ៖

## គោលដៅជាយុទ្ធសាស្ត្ររបស់គណបក្ស

**១**- ការពារសន្តិភាព ការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី និងរាល់សមិទ្ធផលនៃសង្គមជាតិឱ្យបានរឹងមាំ ស្ថិតស្ថេរ គង់វង្ស។

**២**- កសាងព្រះរាជាណាចក្រកម្ពុជា ជារដ្ឋប្រជាធិបតេយ្យសេរី ពហុបក្សដ៏ជឿនលឿន និងរឹងមាំលើគន្លងនីតិរដ្ឋ មានការគោរពសិទ្ធិមនុស្ស មានសេដ្ឋកិច្ចរីកចម្រើនប្រកបដោយចីរភាព និងសមធម៌ ប្រជាជនមានជីវភាពសម្បូរសប្បាយ បានរស់នៅយ៉ាងសុខដុមរមនាប្រកបដោយកិត្តិយស និងសេចក្ដីថ្លៃថ្នូរ ។

**៣**- អភិវឌ្ឍប្រព័ន្ធគាំពារសង្គមប្រកបដោយភាពសមាហរណ សង្គតិភាព បរិយាបន្ន និងចីរភាពហិរញ្ញវត្ថុ ដែលផ្ដល់ការគាំពារដល់ប្រជាជនប្រកបដោយប្រសិទ្ធភាពក្នុងការឆ្លើយតបចំពោះហានិភ័យសេដ្ឋកិច្ច ហានិភ័យសុខភាពសាធារណៈ និងភាពងាយរងគ្រោះនានា ដែលកើតឡើងពីការប្រែប្រួលស្ថានភាពសង្គម-សេដ្ឋកិច្ច លក្ខខណ្ឌនៃការងារ និងការរស់នៅ។

**៤**- ជំរុញការអនុវត្ត "កម្ពុជាគ្មានមីនត្រឹមឆ្នាំ ២០២៥" និងកាត់បន្ថយគ្រាប់មិនទាន់ផ្ទុះឱ្យបានជាអតិបរមា។

**៥**- ប្រកាន់ខ្ជាប់នយោបាយការបរទេសឯករាជ្យដោយផ្អែកលើច្បាប់ កសាងមិត្តភាព និងកិច្ចសហប្រតិបត្តិការល្អប្រសើររវាងព្រះរាជាណាចក្រកម្ពុជា ជាមួយប្រទេសទាំងអស់នៅលើពិភពលោក និងអង្គការអន្តរជាតិនានា ហើយចូលរួមយ៉ាងសកម្មចំពោះបុព្វហេតុសន្តិភាព ស្ថិរភាព សន្តិសុខ និងវិបុលភាពក្នុងតំបន់ និងពិភពលោក។

## គោលនយោបាយជាអាទិភាពមួយចំនួននៃកម្មវិធីនយោបាយរបស់គណបក្ស

**១-** ជ្រោងទង់មហាសាមគ្គីជាតិនៅក្រោមដំបូលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងក្រោមម្លប់នៃ **អង្គព្រះមហាក្សត្រជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** សំដៅបង្រួបបង្រួមប្រមូលកម្លាំងប្រជាជាតិខ្មែរទាំងមូល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ អតីតកាល ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀត ដើម្បីកសាង និងការពារមាតុភូមិ។

**២-** ការពាររបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ប្រឆាំងដាច់ខាតរាល់សកម្មភាពដែលធ្វើឱ្យប៉ះពាល់ដល់ **អង្គព្រះមហាក្សត្រជាទីសក្ការៈ** បន្តពង្រឹងពង្រីកលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស និងនីតិរដ្ឋ ឱ្យចាក់គ្រឹះកាន់តែរឹងមាំពីថ្នាក់ជាតិរហូតដល់មូលដ្ឋាន ការពារ និងលើកស្ទួយសិទ្ធិសេរីភាពគ្រប់យ៉ាងរបស់ប្រជាជន។

**៣-**ថែរក្សាសន្តិភាព និងកេរដំណែលជាប្រវត្តិសាស្ត្ររបស់គណបក្ស ជាពិសេសភាពជោគជ័យក្នុងការអនុវត្តនយោបាយ ឈ្នះ ឈ្នះ ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាស្ថាបនិកមគ្គុទ្ទេសក៍ឯក ដែលបានបញ្ចប់សង្គ្រាមស៊ីវិលទាំងស្រុងនៅកម្ពុជា និងធ្វើឱ្យប្រទេសជាតិមានសុខសន្តិភាព និងការឯកភាពជាតិពេញលេញ។

**៤-** ថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមឱ្យបានរឹងមាំ ទប់ស្កាត់ និងកម្ចាត់រាល់ទម្រង់នៃនយោបាយ និងសកម្មភាពរបស់ពួកជ្រុលនិយម និងមជ្ឈដ្ឋានអគតិនានាដែលប៉ុនប៉ងនាំកម្ពុជាឱ្យឃ្លាតចេញពីមាគ៌ាប្រជាធិបតេយ្យ និងនីតិរដ្ឋ បង្កការបែកបាក់ជាតិ បំផ្លាញសន្តិភាពស្ថិរភាពនយោបាយ និងដំណើរការប្រជាធិបតេយ្យនៅកម្ពុជា ដើម្បីធានាការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងភាពសុខសាន្តជូនប្រជាជនទាំងផ្លូវកាយ និងផ្លូវចិត្ត។

**៥-** ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ទាំងនៅទីក្រុង ទីប្រជុំជន និងជនបទ ប្រកបដោយចីរភាព សមធម៌ និងបរិយាបន្ន ខិតខំធានាស្ថិរភាពសេដ្ឋកិច្ច និងជំរុញកំណើនសេដ្ឋកិច្ចខ្ពស់ ទន្ទឹមនឹងការពង្រឹងភាពធន់នៃសេដ្ឋកិច្ច និងសង្គម ដោយប្រកាន់ខ្ជាប់បាវចនា "**កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព**" និងអាទិភាពគន្លឹះទាំង ៥ គឺ "**មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា**"។

**៦-** បន្តជំរុញការកែទម្រង់រដ្ឋស៊ីជម្រៅ និងទូលំទូលាយតាមអភិក្រម «**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**» រួមមាន ការកែទម្រង់រដ្ឋបាលសាធារណៈ, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌, ការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងការកែទម្រង់ក្នុងវិស័យអាទិភាពផ្សេងៗទៀត ដើម្បីធានានូវអភិបាលកិច្ចល្អ យុត្តិធម៌សង្គម ការផ្តល់សេវាសាធារណៈជូនប្រជាជនប្រកបដោយគុណភាព និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម។

**៧-** ពង្រឹងរដ្ឋបាលសាធារណៈនៅគ្រប់ថ្នាក់ឱ្យក្លាយជារដ្ឋបាលទំនើប មានសមត្ថភាព និងស្អាតស្អំ ជារដ្ឋបាលរបស់ប្រជាជន និងបម្រើផលប្រយោជន៍របស់ប្រជាជនពិតប្រាកដ។

**៨-** រក្សាស្ថិរភាពក្នុងការរស់នៅរបស់ប្រជាជន តាមរយៈការអភិវឌ្ឍ និងការពង្រឹងប្រព័ន្ធគាំពារសង្គម ដែលរួមមាន ប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព និងចីរភាព ដែលជួយគាំពារប្រជាជនគ្រប់រូប ជាពិសេសគ្រួសារក្រីក្រ ក្រុមជនងាយរងគ្រោះ និងគ្រួសារងាយរងហានិភ័យពីគ្រោះអាសន្ន និងវិបត្តិនានា ដោយមិនទុកឱ្យប្រជាជនណាម្នាក់ទទួលរងគ្រោះដោយពុំមានការយកចិត្តទុកដាក់នោះឡើយ។



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ :** ០០២ **គ.ជ.ប**.ស.ប្រ.ក

# បណ្ណប្រកាស
# ស្តីពី
# ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ( គ. ជ. ប)** សូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់ឱ្យបានជ្រាបថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី៤ ហៅកាត់ថា **ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា** នឹងប្រព្រឹត្តទៅនៅ**ថ្ងៃអាទិត្យ ទី២៦ ខែឧសភា ឆ្នាំ២០២៤**។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា គឺជាការបោះឆ្នោតអសកល ដែលមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងមុខតំណែងជាអ្នកបោះឆ្នោត ដើម្បីជ្រើសរើសក្រុមប្រឹក្សា ២ប្រភេទ គឺក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត និងក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។ ការបោះឆ្នោតនេះមានភាពខុសប្លែកពីការបោះឆ្នោតផ្សេងទៀតដែលរៀបចំដោយ គ.ជ.ប ព្រោះអ្នកបោះឆ្នោតម្នាក់ៗត្រូវបោះឆ្នោតពីរសន្លឹក ដោយមានហិបឆ្នោតចំនួនពីរ ដើម្បីជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនីមួយៗ៖

- សន្លឹកឆ្នោតទី១ មាន**ពណ៌ផ្ទៃមេឃ**ប្រើក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់ដាក់ក្នុងហិបឆ្នោតមួយ
- សន្លឹកឆ្នោតទី២ មាន**ពណ៌ស**ប្រើក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត សម្រាប់ដាក់ក្នុងហិបឆ្នោតមួយផ្សេងទៀត។

❈ **ចំនួនមណ្ឌលបោះឆ្នោត និងសមាជិកក្រុមប្រឹក្សា សម្រាប់អាណត្តិទី៤ នេះ មានដូចខាងក្រោម ៖**

- **មណ្ឌលរាជធានី ខេត្ត ទូទាំងប្រទេសសរុបចំនួន ២៥ មានសមាជិកក្រុមប្រឹក្សាសរុបចំនួន ៥៥៩**
- **មណ្ឌលក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេសសរុបចំនួន ២០៩ មានសមាជិកក្រុមប្រឹក្សាសរុបចំនួន ៣.៦៤១។**

❈ **ចំនួនអ្នកបោះឆ្នោត និងចំនួនការិយាល័យបោះឆ្នោត មានដូចខាងក្រោម ៖**

- **អ្នកបោះឆ្នោត ដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងមុខតំណែង មានចំនួនសរុប ១១.៦២២ នាក់**
- **ការិយាល័យបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា មានចំនួនសរុប ២០៩ ដែលមានទីតាំងនៅទីប្រជុំជនក្រុង ស្រុក ខណ្ឌ។**

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ជ្រាបជាព័ត៌មាន និងចូលរួមតាមដានដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានេះ កុំបីអាក់ខាន។/.

ថ្ងៃច័ន្ទ ៦ កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០២៤

**ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**អគ្គលេខាធិការដ្ឋាន**
លេខ : ✓ គ.ជ.ប.អគ្គ

**តារាងម៉ោងផ្សាយកម្មវិធីស្មើភាព**
**សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី**
**ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤**
**នៅទូរទស្សន៍ជាតិកម្ពុជា (ទទក) និងវិទ្យុជាតិកម្ពុជា**
(ផ្សាយពីថ្ងៃទី១៧ ខែឧសភា ដល់ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤)

| ពេលវេលា | ទូរទស្សន៍ជាតិកម្ពុជា (ទទក) | វិទ្យុជាតិកម្ពុជា | | |
|---|---|---|---|---|
| | | AM 918KHz | FM 105.70MHz | FM 96MHz |
| ព្រឹក | ១០:០០-១២:៣០ នាទី | ៧:០០-៩:៣០ នាទី | ៧:០០-៩:៣០ នាទី | ៨:០០-១០:៣០ នាទី |
| រសៀល | ១៣:០០-១៥:៣០ នាទី | | | |
| ល្ងាច | - | ១៥:០០-១៧:៣០ នាទី | ១៥:០០-១៧:៣០ នាទី | ១៦:០០-១៨:៣០ នាទី |

គ.ជ.ប

# គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤

(ថ្ងៃអាទិត្យ ទី២៦ ខែឧសភា ឆ្នាំ២០២៤)

## គណបក្សប្រជាជនកម្ពុជា
ប្រ.ជ

## គណបក្ស ឆន្ទៈខ្មែរ
គ.ឆ.ខ

## គណបក្ស កម្លាំងជាតិ
គ.ក.ជ

## គណបក្សហ្វ៊ុនស៊ិនប៉ិច
រ.រ.ជ.ក.ឯ.អ.ស.ស

## គណបក្សខ្មែររួបរួមជាតិ
ខ.រ.ជ

**កំណត់សម្គាល់ ៖ នេះមិនមែនជាសន្លឹកឆ្នោតទេ**